អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

Coalition for Partnership in Democratic Development (CPDD)

# គោលការណ៍ណែនាំ
# ស្តីពី
# ការចូលជាអង្គការសមាជិក



កក្កដា ២០២១

I. អំពីអង្គការសម្ព័ន្ធភាពដៃគូអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ........ 3

❖ ទស្សនវិស័យ៖ ........ 3

❖ បេសសកម្ម៖ ........ 3

❖ គោលបំណង៖ ........ Error! Bookmark not defined.

❖ គោលដៅ៖ ........ Error! Bookmark not defined.

II. អត្ថប្រយោជន៍នៃសមាជិកភាពរបស់អង្គការ CPDD ........ 4

១ . ចូលរួមកម្មវិធី កិច្ចប្រជុំ និងការចែករំលែកព័ត៌មាន ផ្លាស់ប្តូរបទពិសោធន៍ ........ 4

២. ការកសាង និងពង្រឹងសមត្ថភាពនៅក្នុងកម្រិតបុគ្គលិក និងស្ថាប័នទាំងមូល ........ 4

៣ ពង្រីកឈ្មោះ និងវិសាលភាពក្នុងការធ្វើការងារជាបណ្តាញនៅកម្រិតថ្នាក់ជាតិ និងអន្តរជាតិ ........ 5

៤. ការពង្រឹងយន្តការស្វែងរកមតិគាំទ្ររួម និងជាតំណាងឲ្យអង្គការក្នុងវិស័យសិទ្ធិកុមារ Error! Bookmark not defined.

៥. .ទទួលបានព័ត៌មាន និងទិន្នន័យថ្មីៗ ........ 5

៦. .ទទួលបានវិញ្ញាបនបត្រប្រចាំឆ្នាំ ........ 6

III. លក្ខខណ្ឌអង្គការ ឬសមាគមដែលអាចចូលជាសមាជិកអង្គការ CPDD ........ 8

១. ឯកសារដែលតម្រូវ សម្រាប់ការសុំចូលជាសមាជិកអង្គការ ........ 10

២. ដំណើរការនីតិវិធីនៃការដាក់ពាក្យសុំ : ........ 10

៣. អំពីការសម្រេចលើពាក្យសុំ៖ ........ 11

IV. តួនាទី ភារកិច្ច និងការបាត់បង់សមាជិកភាព ........ 12

ក.ចំពោះសមាជិកបម្រុង៖ ........ 12

ខចំពោះសមាជិកពេញសិទ្ធិ៖ ........ 12

គ. ការបាត់បង់សមាជិកភាពពីអង្គការ ........ 13

V. ប្រាក់វិភាគទាន នីតិវិធីនៃការបង់ និងប្រើប្រាស់វិភាគទាន អង្គការសមាជិកភាពប្រចាំឆ្នាំ. 14

ក. ប្រាក់វិភាគទាន៖ ........ 14

ខ. និតិវិធីនៃការបង់វិភាគទាន ........ 14

គ. ការប្រើប្រាស់វិភាគទាន និងសិទ្ធិសម្រេច ........ 14

ឃ. ព័ត៌មានទំនាក់ទំនងសម្រាប់ដាក់ពាក្យស្នើសុំចូលជាសមាជិកភាព ........ 15

VI. **ការកែប្រែគោលការណ៍ នីតិវិធី និងសិទ្ធិសម្រេច** ........ 16

ក. ការកែប្រែគោលការណ៍ ........ 16

ខ. នីតិវិធី និងសិទ្ធិសម្រេច ........ 16

## I. អំពីអង្គការសម្ព័ន្ធភាពដៃគូ ដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (អ.ស.ដ.គ.ជ.អ.ប)

### ❖ ទស្សនវិស័យ៖

សង្គមកម្ពុជាដែលប្រជាពលរដ្ឋគ្រប់រូបអាចចូលរួមពិតប្រាកដ នៅក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងមានលទ្ធភាពដោយស្មើភាពគ្នា ក្នុងការទទួលបានសេវាសាធារណៈដែលមានគុណភាព និងឆ្លើយតបចំពោះតម្រូវការរបស់ពួកគេ។

### ❖ បេសសកម្ម៖

ដើម្បីលើកកម្ពស់សំឡេងរួម និងការចូលរួមប្រកបដោយអត្ថន័យរបស់សង្គមស៊ីវិល ជាមួយនឹងរដ្ឋាភិបាល នៅគ្រប់កម្រិតថ្នាក់ទាំងអស់សំដៅពង្រឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ។

### ❖ អំពីគោលបំណង

-លើកកម្ពស់ការរៀនសូត្រ និងចែករំលែកក្នុងចំណោមបណ្តាញសង្គមស៊ីវិលនានាអំពីការអភិវឌ្ឍមូលដ្ឋានប្រកបដោយតម្លាភាព គណនេយ្យភាព និងការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងសមភាព

-ពង្រឹងប្រព័ន្ធចូលរួមតាមបែបប្រជាធិបតេយ្យតាមរយៈសកម្មភាពនៃភាពជាដៃគូនានា ក្នុងចំណោមអ្នក ដែលធ្វើការងារពាក់ព័ន្ធ នឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

-សម្របសម្រួលសំឡេងរួមរបស់អង្គការសង្គមស៊ីវិលអំពីបញ្ហានៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

### ❖ អំពីគោលដៅ

**គោលដៅរបស់អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរួមមាន៖**

-ពង្រឹងសមត្ថភាពរបស់សង្គមស៊ីវិលនៅក្នុងការលើកកម្ពស់ការអភិវឌ្ឍមូលដ្ឋានប្រកបដោយតម្លាភាព គណនេយ្យភាព និងការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងសមភាព។

-ចូលរួមលើកកម្ពស់ភាពជាដៃគូររវាងរដ្ឋាភិបាល និងសង្គមស៊ីវិល នៅគ្រប់កម្រិតទាំងអស់សំដៅបង្កើន ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងសកម្មភាពអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ។

## II. អត្ថប្រយោជន៍នៃសមាជិកភាពរបស់អង្គការ (អ.ស.ជ.គ.ជ.អ.ប)

នៅក្នុងប្រទេសកម្ពុជាមានអង្គការក្នុងស្រុកជាច្រើន និងអង្គការអន្តរជាតិជាច្រើនកំពុងធ្វើការលើវិស័យផ្សេងគ្នា ក្នុងការជម្រុញអោយមានការអភិវឌ្ឍសង្គម ដោយផ្អែកលើយន្តការចូលរួមរបស់ប្រជាពលរដ្ឋ។ គោលបំណង នៃការបន្តពង្រីកបណ្តាញអង្គការសមាជិកគឺដើម្បីពង្រឹងបណ្តាញ អង្គការអោយមានភាពរឹងមាំ ក្នុងការជំរុញ ការស្វែងរកមតិគាំទ្រតាំងពីកម្រិតថ្នាក់ភូមិតាមរយៈអង្គការសមាជិករហូតដល់កម្រិតថ្នាក់ជាតិ។ មួយវិញទៀត ពង្រឹងសមត្ថភាពរបស់សង្គមស៊ីវិលនៅក្នុងការលើកកម្ពស់ការអភិវឌ្ឍមូលដ្ឋានប្រកបដោយតម្លាភាព គណនេយ្យភាព និងការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងសមភាព និងចូលរួមលើកកម្ពស់ ភាពជាដៃគូររវាងរដ្ឋាភិបាល និងសង្គមស៊ីវិល នៅគ្រប់កម្រិតទាំងអស់សំដៅបង្កើន ការចូលរួមរបស់ប្រជា ពលរដ្ឋនៅក្នុងសកម្មភាពអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ។ ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដែលជាសមាជិករបស់អង្គការនឹងទទួលបានអត្ថប្រយោជន៍ដូចខាងក្រោមៈ

### ១.ចូលរួមកម្មវិធីកិច្ចប្រជុំ និងការចែករំលែកព័ត៌មាន ផ្លាស់ប្តូរបទពិសោធន៍

អង្គការសមាជិកនឹងទទួលបានការអញ្ជើញចូលរួមប្រជុំយ៉ាងទៀងទាត់រៀងរាល់ត្រីមាស៣ខែម្តង ក្នុង ចំណោមអង្គការសមាជិក និងក្រុមការងារតាមវិស័យ កម្មវិធីសន្និបាតប្រចាំឆ្នាំ និងចូលរួមកម្មវិធីផ្សេងៗទៀត ដែលរៀបចំ និងសម្របសម្រួលដោយអង្គការ CPDD។ បន្ថែមពីនោះ អង្គការសមាជិកនឹងចូលរួមក្នុងការ ពិគ្រោះយោបល់ សិក្ខាសាលា កិច្ចពិភាក្សា និងការចែករំលែកអំពីបទពិសោធន៍ជោគជ័យ ជាពិសេសការអនុវត្ត ការងារល្អៗ ពីសំណាក់អង្គការសមាជិកនីមួយៗទាំងអង្គការក្នុងស្រុក និងអង្គការអន្តរជាតិ ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងបុគ្គលិកនៃអង្គការ និងអាចចូលពិគ្រោះយោបល់ជាមួយរដ្ឋាភិបាល។

### ២. ការកសាង និងពង្រឹងសមត្ថភាពនៅក្នុងកម្រិតបុគ្គលិក និងស្ថាប័នទាំងមូល

អង្គការCPDD ធ្វើការស្ទង់មតិជារៀងរាល់ឆ្នាំ ដើម្បីវាស់ស្ទង់ពីកម្រិតសមត្ថភាព ការពេញចិត្ត ឬមិន ពេញចិត្តទៅលើការសម្របសម្រួល ចំណុចគួរពង្រឹងបន្ថែមរបស់អង្គការ CPDD និងតម្រូវការដែលអង្គការ សមាជិកត្រូវការទាំងផ្នែកធនធានមនុស្ស ហិរញ្ញវត្ថុ និងបច្ចេកទេស។ ជារៀងរាល់ឆ្នាំ អង្គការ CPDD តែងតែ បាន ផ្តល់នូវវគ្គបណ្តុះបណ្តាលទៅលើប្រធានបទផ្សេងៗគ្នាជាច្រើន រួមមាន ជំនាញតស៊ូមតិ កៀងគរការគាំទ្រ ការផ្ទេរមុខងារពីថ្នាក់ជាតិ មកថ្នាក់ក្រោមជាតិ ការយល់ដឹងអំពីទូនាទីក្រុង/ស្រុក ការសិក្សាលើយន្តការចូលរួម របស់ប្រជាពលរដ្ឋ គោលនយោបាយសាធារណៈ ចែករំលែកព័ត៌មាន និងការស្វែងរកមូលនិធិគាំទ្រជាដើម ជូន ដល់អង្គការសមាជិក ដើម្បីពង្រឹងសមត្ថភាពបុគ្គលិក និងស្ថាប័នរបស់ពួកគេដោយផ្អែកទៅតាមតម្រូវការរបស់ អង្គការសមាជិក។ អង្គការ CPDD រៀបចំវគ្គបណ្តុះបណ្តាល ទៅដល់អង្គការសមាជិកយ៉ាងតិចបំផុត បួនដង ក្នុងមួយឆ្នាំ ហើយជំរុញការអភិវឌ្ឍស្ថាប័នដើម្បីធានាថា អង្គការសមាជិកទទួលបាននូវការអភិវឌ្ឍទាំងកម្រិត

ស្ថាប័ន និងកម្រិតបុគ្គលិក ព្រមទាំងស្របទៅតាមផ្លូវច្បាប់ ឬគោលនយោបាយសាធារណៈ។ អង្គការសមាជិកក៏ត្រូវបានលើកទឹកចិត្ត គាំទ្រ និងជំរុញឱ្យចូលរួមជាមួយអង្គការ CPDD ក្នុងការសរសេរ ឬដាក់គម្រោងសំណើរផ្សេងៗផងដែរ ដើម្បីអនុវត្តគម្រោង។ មិនត្រឹមតែប៉ុណ្ណោះ បច្ចុប្បន្នអង្គការ CPDD បានសហការជាមួយអង្គការសមាជិក (អង្គការជាតិ) នៅតាមបណ្តាខេត្ត និងភ្នំពេញ ដើម្បីដាក់ស្នើសុំគម្រោងជាច្រើន ដើម្បីធានាថាស្ថាប័នរបស់ពួកគេមានដំណើរការបន្តសកម្មភាពការងារក្នុងការលើកកម្ពស់សំឡេង និងការចូលរួមរបស់ប្រជាពលរដ្ឋ តាមរយៈការគាំទ្រសកម្មភាពរបស់អង្គការសមាជិក។

### ៣. ពង្រីកឈ្មោះ និងវិសាលភាពក្នុងការធ្វើការងារជាបណ្តាញនៅកម្រិតថ្នាក់ជាតិ និងអន្តរជាតិ

អង្គការ CPDD ធ្វើការយ៉ាងជិតស្និត និងមានទំនាក់ទំនងល្អជាមួយបណ្តាអង្គការដៃគូ ស្ថាប័នជាតិ និងអន្តរជាតិ ព្រមទាំងត្រូវបានទទួលស្គាល់ថា ជាអង្គការសម្ព័ន្ធ ដែលធ្វើការពង្រឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងមានលទ្ធភាពដោយស្មើភាពគ្នា ក្នុងការទទួលបានសេវាសាធារណៈ ដែលមានគុណភាព និងឆ្លើយតបចំពោះតម្រូវការរបស់ពួកគេយ៉ាងមានសក្តានុពលក្នុងប្រទេសកម្ពុជា។ អង្គការសមាជិកជាផ្នែកមួយយ៉ាងសំខាន់ក្នុងការជំរុញឱ្យយន្តការ និងដំណើរការនេះអាចប្រព្រឹត្តិទៅបាន។ លើសពីនេះទៅទៀតអង្គការសមាជិកត្រូវបានគេទទួលស្គាល់ច្រើនតាមរយៈបណ្តាញព័ត៌មានសង្គម ដូចហ្វេសប៊ុកផេក និងគេហទំព័រ ជាងនេះទៅទៀត មានឱកាសច្រើនចំពោះការចងជាបណ្តាញ ឬទំនាក់ទំនងជាមួយអង្គការ សមាគម តាំងពីកម្រិតថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ រហូតដល់ថ្នាក់តំបន់ ជាពិសេសនៅលើឆាកអន្តរជាតិ តាមរយៈការស្គាល់ពីឡូហ្គោចូលរួមធ្វើរបាយការណ៍ និងកិច្ចប្រជុំជាមួយ គ.ជ.អ.ប ។ មិនត្រឹមតែប៉ុណ្ណោះ ឡូហ្គោរបស់អង្គការសមាជិកនឹងត្រូវបានប្រើប្រាស់ក្នុងនាមជាសមាជិករបស់អង្គការ CPDD នៅលើគេហទំព័រ ដែលនេះជាការលើកកម្ពស់នូវកេត្តនាមរបស់អង្គការសមាជិក និងផ្សព្វផ្សាយពីការងាររបស់អង្គការសមាជិកលើបណ្តាញសង្គម។ អ្នកទស្សនាអាចចូលស្វែងរកព័ត៌មានបឋមរបស់អង្គការសមាជិកនៅលើគេហទំព័ររបស់អង្គការ CPDD។

### ៤ .ការពង្រឹងយន្តការស្វែងរកមតិគាំទ្ររួម និងជាតំណាងឲ្យអង្គការសមាជិក

- ✓ សមាជិក CPDD ធ្វើការរួមគ្នាដើម្បីបង្កើនឥទ្ធិពលនៃសម្លេងរបស់ពួកគេ ក្នុងការស្វែងរកមតិគាំទ្រទៅលើពង្រឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងមានលទ្ធភាពដោយស្មើភាពគ្នា ក្នុងការទទួលបានសេវាសាធារណៈនៅក្នុងប្រទេសកម្ពុជា។ ជាពិសេសអង្គការ ផ្តោតទៅលើការបង្កើត និងកែប្រែច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តផ្សេងៗដែលពាក់ព័ន្ធទៅនឹងយន្តការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។
- ✓ អង្គការ CPDD តំណាងឲ្យសមាជិករបស់ខ្លួននៅគ្រប់សកម្មភាព និងក្នុងនាមសមាជិកទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ ។

- ✓ អង្គការ CPDD ទទួលយកនូវក្តីបារម្ភផ្សេងៗពាក់ព័ន្ធនឹងបញ្ហារបស់សមាជិកខ្លួន ដែលបានលើកឡើង ហើយរៀបចំលិខិតដោយមានការពន្យល់ និងអនុសាសន៍ដាក់ជូនរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងស្ថាប័នអន្តរជាតិ ដែលពាក់ព័ន្ធដើម្បីចាត់វិធានការសមស្របក្នុងការស្វែងរកដំណោះស្រាយសមរម្យ។
- ✓ អង្គការ CPDD មានទំនាក់ទំនងល្អជាមួយ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ( គ.ជ.អ.ប) ក្រសួងសង្គមកិច្ច ក្រសួងកិច្ចការនារី ដៃគូអភិវឌ្ឍន៍ អង្គការដៃគូ និងស្ថាប័នផ្សេងៗទៀត ដើម្បីធ្វើការពិភាក្សា និងផ្តល់អនុសាសន៍ទៅលើបញ្ហាផ្សេងៗដែលពាក់ព័ន្ធលើការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។
- ✓ អង្គការ CPDD មានកិច្ចសហប្រតិបត្តិការល្អ និងចូលរួមធ្វើការជាមួយសង្គមស៊ីវិលជាច្រើនក្នុងប្រទេសកម្ពុជា ដើម្បីប្រមូលផ្តុំមតិគាំទ្រលើបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងលើការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅប្រទេសកម្ពុជា។

## ៦ .ទទួលបានព័ត៌មាន និងទិន្នន័យថ្មីៗ

អង្គការ CPDD ធ្វើការយ៉ាងជិតស្និត និងមានទំនាក់ទំនងល្អជាមួយរាល់បណ្តាអង្គការដៃគូនានា ស្ថាប័នជាតិ និងអន្តរជាតិ ព្រមទាំងត្រូវបានទទួលស្គាល់ថា ជាអង្គការCPDD លើកកម្ពស់សំឡេង ការចូលរួមរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យយ៉ាងមានសក្តានុពលក្នុងប្រទេសកម្ពុជា។ អង្គការសមាជិកជាផ្នែកមួយយ៉ាងសំខាន់ក្នុងការជំរុញឱ្យយន្តការ និងដំណើរការនេះអាចប្រព្រឹត្តិទៅបាន។ លើសពីនេះទៅទៀតអង្គការសមាជិកត្រូវបានគេទទួលស្គាល់ច្រើនតាមរយៈបណ្តាញព័ត៌មានសង្គម ដូចហ្វេសប៊ុកផេករបស់អង្គការ និងគេហទំព័រ ជាងនេះទៅទៀត អង្គការសមាជិកមានឱកាសច្រើនចំពោះការចងជាបណ្តាញ ឬទំនាក់ទំនងជាមួយអង្គការ សមាគម តាំងពីកម្រិតថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ រហូតដល់ថ្នាក់តំបន់ ជាពិសេសនៅលើឆាកអន្តរជាតិ តាមអង្គការ ធ្វើការយ៉ាងជិតស្និត និងមានទំនាក់ទំនងល្អជាមួយបណ្តាអង្គការដៃគូ ស្ថាប័នជាតិ និងអន្តរជាតិ ព្រមទាំងត្រូវបានទទួលស្គាល់ជាអង្គកការសម្ព័ន្ធដែលអាចដោះស្រាយបញ្ហាប្រឈមរបស់អង្គការសមាជិកបាន។ លើសពីនេះទៅទៀតអង្គការសមាជិកត្រូវបានគេទទួលស្គាល់ច្រើនតាមរយៈបណ្តាញព័ត៌មានសង្គម អង្គការ CPDD តែងផ្ញើរជូននូវព័ត៌មាន ក៏ដូចជារាយការណ៍ជាបន្តបន្ទាប់ ជុំវិញព័ត៌មានទាក់ទងទៅនឹងស្ថានភាពសិទ្ធិមនុស្ស ជាពិសេសកិច្ចការងារដែលពាក់ពន្ធ័ជា ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ឬព័ត៌មានផ្សេងៗ តាមរយៈកិច្ចប្រជុំអង្គការសមាជិក កិច្ចប្រជុំក្រុមការងារតាមវិស័យទាំង៥ វិស័យ និងតាមរយៈប្រព័ន្ធសារអេឡិចត្រូនិច។ល។ ជាមួយគ្នានេះផងដែរ អង្គការទទួលបានការចែករំលែកព័ត៌មានក្នុងចំណោមដៃគូពាក់ព័ន្ធផ្សេងៗ។ រាល់ទិន្នន័យ និងព័ត៌មានទាំងអស់គឺអង្គការCPDD បានចែកជូនទៅដល់អង្គការសមាជិកដែលមានប្រភពច្បាស់លាស់។

### ៧. ទទួលបានវិញ្ញាបនបត្រប្រចាំឆ្នាំ

អង្គការសមាជិក ដែលបានចូលរួមសកម្មភាពយ៉ាងសកម្មពេញមួយឆ្នាំជាមួយអង្គការ CPDD នឹងទទួលបានវិញ្ញាបនបត្រប្រចាំឆ្នាំដែលចេញដោយអង្គការCPDD។ លក្ខណវិនិច្ឆ័យសកម្មភាពនានាដែលកំណត់នូវសមាជិកសកម្មមានដូចខាងក្រោម៖

*១/. ចូលរួមការប្រជុំអង្គការសមាជិកប្រចាំត្រីមាស (យ៉ាងតិច៣ដង)*

*២/. ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ (យ៉ាងតិច២ដង)*

*៣/. ចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ (យ៉ាងតិច២ដង)*

*៤/. ចូលរួមស្វែងរកមតិគាំទ្រដូចជាជំនួបជាមួយណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ( គ.ជ.អ.ប) និងគាំទ្រលើសេចក្តីថ្លែងការផ្សេងៗ (យ៉ាងតិច២ដង)*

អង្គការ CPDD នឹងប្រគល់វិញ្ញាបនបត្រប្រចាំឆ្នាំនៅរៀងរាលចុងឆ្នាំក្នុងកម្មវិធីសន្និបាតប្រចាំឆ្នាំរបស់អង្គការ។ វិញ្ញាបនបត្រប្រចាំឆ្នាំនេះនឹងផ្តល់ជូនដល់អង្គការសមាជិកដែលមានសកម្មភាពដូចបានរៀបរាប់ខាងលើ។ លើសពីនេះទៅទៀត វិញ្ញាបនបត្រប្រចាំឆ្នាំនេះបង្ហាញពីភាពសកម្មរបស់អង្គការសមាជិកក្នុងការចុលរួមរាល់សកម្មភាពជាមួយ អង្គការ CPDD ដើម្បីលើកកម្ពស់ សំឡេងប្រជាពលរដ្ឋ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា។

## III. លក្ខខណ្ឌអង្គការ ដែលអាចចូលជាសមាជិកអង្គការ

គឺបើកចំហដល់បុគ្គល ឬ ស្ថាប័នដែលផ្តល់ជំនួយមនុស្សធម៌ ដើម្បីលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច ប្រជាធិតេយ្យ សិទ្ធិមនុស្ស សិទ្ធិកុមារ ចីរភាពនៃបរិស្ថាន និងសង្គម ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងវិស័យផ្សេងៗទៀត ដែល មិនទាក់ទងនឹងសាសនា និងនយោបាយ។ សមាជិកគឺជាអ្នកដើរតួរសំខាន់បំផុតក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់ អង្គការ សម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)។ ពួកគេជាអ្នកជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាល និងផ្តល់ទិសដៅអនុម័តផែនការយុទ្ធសាស្ត្ររបស់អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនិងចូលរួមនិងត្រួតពិនិត្យការអនុវត្តផែនការរបស់ អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)។ ពួកគេគឺជាស្នូលរបស់ អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD) ក្នុងការធ្វើការតស៊ូមតិ ការរៀនសូត្រ និងចែករំលែកចំណេះដឹងប្រកបដោយប្រសិទ្ធភាពដែលជាផ្នែកមួយដ៏ សំខាន់នៃសកម្មភាពដែលកំពុង អនុវត្តរបស់(CPDD)។ រាល់សមាជិករបស់អង្គការទាំងអស់ត្រូវគោរព និងអនុវត្តទៅតាមច្បាប់នានា លិខិតបទដ្ឋាន គតិយុត្តនានា នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងរាល់សេចក្តី សម្រេចរបស់អង្គការ។

**ដើម្បីចូលជាសមាជិក អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD) ស្ថាប័នត្រូវបំពេញនូវលក្ខខណ្ឌខាងក្រោម ៖**

១- ចុះឈ្មោះតាមរយៈការបំពេញពាក្យចូលជាសមាជិក

២-មានតម្លាភាពចំពោះសេចក្តីសម្រេចដែលធ្វើឡើងដោយអង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)

៣- ផ្តល់ធាតុចូលទៅក្នុងការរៀបចំផែនការ និងកិច្ចប្រជុំនានា

៤- ផ្តល់ថវិកាដើម្បីជួយទ្រទ្រង់សកម្មភាពរបស់អង្គការដែលទាក់ទងនឹង អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)

៥- ដឹកនាំ ឬគាំទ្រសកម្មភាពរបស់ អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)

៦- ភ្ជាប់ទំនាក់ទំនងនិងគាំទ្រអនុក្រុមប្រឹក្សាភិបាលចម្រុះ

៧- មានសិទ្ធឈរឈ្មោះជា បេក្ខជនសម្រាប់សមាជិកភាពក្រុមប្រឹក្សាភិបាល អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យ (CPDD)

**ដើម្បីចូលជាសមាជិក អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD) រូបវន្តបុគ្គលត្រូវបំពេញនូវលក្ខខណ្ឌ ដូចខាងក្រោម ៖**

១- ជាបុគ្គលដែលមានកេរ្តិ៍ឈ្មោះល្អ ក្នុងវិស័យ អភិបាលមូលដ្ឋាន តាមបែបប្រជាធិបតេយ្យ និងការអភិវឌ្ឍសង្គមក្នុងប្រទេសកម្ពុជា និងក្នុងតំបន់

២- ជាអ្នកជំនាញក្នុងកិច្ចការអភិបាលកិច្ចមូលដ្ឋាន និងវិមជ្ឈការ

៣- មានបទពិសោធន៍យ៉ាតតិច ៦ ឆ្នាំ ក្នុងអភិបាលកិច្ចថ្នាក់ជាតិ និងតំបន់

៤-មានលទ្ធភាពចែករំលែកចំណេះដឹង និងមានជំនាញ និងពេលវេលាដើម្បីជួយពង្រឹងអង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ(CPDD) ស្តីពីអភិបាលកិច្ចមូលដ្ឋាន និងកំណែរទម្រង់វិមជ្ឈការនានា។

**សមាជិកទាំងអស់មាន តួនាទី និងការទទួលខុសត្រូវដូចខាងក្រោម៖**

១- ចែករំលែកការអនុវត្តល្អ ជោគជ័យ បញ្ហា ព័ត៌មាន និងចំណេះដឹងជាមួយគ្នាទៅវិញទៅទាក់ទង និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

២- ផ្សព្វផ្សាយព័ត៌មានទៅអ្នកពាក់ព័ន្ធ

៣- ប្រមូលសំឡេងរួម និងចែករំលែកជាមួយអង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

៤- ចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រជុំនានា

៥- រួមចំណែកធ្វើឱ្យប្រសើរឡើងដល់អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

**ដំណើរការក្នុងការចុះឈ្មោះចូលជាសមាជិកអង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD) មានដូចខាងក្រោម ៖**

១- អានលក្ខខន្តិកៈរបស់អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)

២- បំពេញបែបបទដាក់ចូលជាសមាជិក

៣-ដាក់ពាក្យចូលជាសមាជិកទៅការិយាល័យអង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

៤- ការិយាល័យអង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD) ពិនិត្យពាក្យសុំចូលជាសមាជិក

៥- ស្វែងរកការអនុម័តចូលជាសមាជិកពីក្រុមប្រឹក្សាភិបាលអង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)

៦- អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD) នឹងជូនដំណឹងអំពីសំណើសុំចូលជាសមាជិកក្នុងរយៈពេល ២ សប្តាហ៍។

## ១. ឯកសារដែលតម្រូវ សម្រាប់ការសុំចូលជាសមាជិក

បុគ្គល ឬស្ថាប័ន ដែលជាអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលមានបំណងចង់ចូលជាសមាជិករបស់អង្គការ ត្រូវចូលរួមបំពេញសំណុំបែបបទដូចខាងក្រោមៈ

| | |
|---|---|
| *១. ពាក្យសុំចូលជាសមាជិក* | *០១ ច្បាប់* |
| *២. លក្ខន្តិកៈដែលមានសុពលភាព* | *០១ ច្បាប់* |
| *៣. លិខិតអនុញ្ញាតិច្បាប់ដោយក្រសួងពាក់ព័ន្ធ* | *០១ ច្បាប់ (ថតចម្លង)* |
| *៤. របាយការសកម្មភាពប្រចាំឆ្នាំចុងក្រោយ* | *០១ ច្បាប់* |
| *៥. របាយការណ៍សង្ខេបពីស្ថាប័ន* | *០១ ច្បាប់* |
| *៦. សេចក្តីប្រកាសវិភាគទានសមាជិកភាពប្រចាំឆ្នាំ* | *០១ ច្បាប់* |
| *៧. ឡូហ្គោ (រូបភាពដើម)* | *ចំនួន ០១* |

## ២. ដំណើរការនីតិវិធីនៃការដាក់ពាក្យសុំ :

- ផ្នែកការអភិវឌ្ឍសមាជិកភាពនៃ អង្គការ មានភារកិច្ចផ្តល់ព័ត៌មានអំពីលក្ខខណ្ឌក្នុងការសុំចូលជាអង្គការសមាជិករបស់អង្គការ ដល់បុគ្គល ឬអង្គការមិនមែនរដ្ឋាភិបាល ដែលស្វែងយល់ពីការសុំចូល ជាអង្គការសមាជិក ឬមានបំណងសុំចូលជាអង្គការសមាជិក។
- ពាក្យសុំចូលជាសមាជិក រួមទាំងឯកសារដូចមានរៀបរាប់ខាងលើ ត្រូវយកមកដាក់នៅការិយាល័យនៃអង្គការ CPDD ឬផ្ញើរតាមប្រពន្ធ័អ៊ីនធ័រណេត នៅរៀងរាល់ម៉ោងធ្វើការ (០៧:៣០ព្រឹក -១៧:០០រសៀល)។
- មន្ត្រីផ្នែកការអភិវឌ្ឍសមាជិកភាពនៃ អង្គការ មានភារកិច្ចទទួលសំណុំបែបបទសុំចូលជាសមាជិក និងត្រួតពិនិត្យរាល់ទំរង់ពាក្យស្នើសុំ។ ក្នុងករណីសំណុំបែបបទពុំមានលក្ខណៈគ្រប់គ្រាន់ដូចមានរៀបរាប់ខាងលើ ផ្នែកការអភិវឌ្ឍសមាជិកភាពនៃ អង្គការ ត្រូវជូនដំណឹងទៅអ្នកស្នើសុំ ដើម្បីបំពេញបន្ថែម។
- ក្នុងករណីសំណុំឯកសារមានលក្ខណៈគ្រប់គ្រាន់ហើយ ឬត្រូវបានបំពេញបន្ថែមហើយ ផ្នែកការអភិវឌ្ឍសមាជិកភាពនៃ អង្គការ ត្រូវរៀបចំព័ត៌មានសង្ខេប ដែលបញ្ជាក់អំពីលេខរៀង ឈ្មោះអង្គការជាភាសាខ្មែរ និងភាសាបរទេស ឈ្មោះប្រធានអង្គការ គោលបំណង ទស្សនវិស័យ បេសកកម្ម និងគុណតម្លៃ អាសយដ្ឋាន កាលបរិច្ឆេទចុះបញ្ជី ឯកសារគាំទ្រ បញ្ជូនមកនាយកប្រតិបត្តិក្នុងរយៈពេលពីរសប្តាហ៍។
- នាយកប្រតិបត្តិត្រូវផ្តល់ពត៌មាន ស្តីពី ការស្នើសុំចូលជាសមាជិកថ្មី និងព័ត៌មានសង្ខេបអំពីអង្គការសាមីនោះ មកគណៈគ្រប់គ្រងក្នុងរយៈពេលពីរសប្តាហ៍ ដើម្បីគណៈគ្រប់គ្រងពិនិត្យមុននឹងដាក់ចូលក្នុងរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងសម្រេច។

### ៣. អំពីការសម្រេចលើពាក្យសុំ

- ក្រុមប្រឹក្សាភិបាលរបស់ អង្គការ CPDD ក្រោយពីបានទទួលពាក្យស្នើសុំចូលជាអង្គការសមាជិក និងព័ត៌មានសង្ខេបពីគណៈគ្រប់គ្រងហើយ ត្រូវដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាល
- ការសម្រេចឲ្យបុគ្គល ឬអង្គការមិនមែនរដ្ឋាភិបាលចូល ឬមិនឲ្យចូលជាសមាជិករបស់អង្គការ ជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាភិបាល។ ការសម្រេចនេះ ត្រូវធ្វើឡើងដោយមតិភាគច្រើន ឬ៥០% បូកមួយ នៃសមាជិកក្រុមប្រឹក្សាភិបាល។
- ដោយមានជំនួយពីបុគ្គលិក អង្គការ CPDD ក្រុមប្រឹក្សាភិបាលត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរយ៉ាងយូរ ០២សប្តាហ៍ ទៅបុគ្គល ឬអង្គការដែលបានដាក់ពាក្យសុំ បន្ទាប់ពីការសម្រេចរបស់ខ្លួន អំពីការអនុញ្ញាត ឬមិនអនុញ្ញាតឲ្យចូលជាសមាជិក។
- ក្រោយពីការសម្រេចរបស់ក្រុមប្រឹក្សាភិបាលឲ្យចូលជាអង្គការសមាជិករបស់អង្គការ បុគ្គល ឬអង្គការដែលស្នើសុំនោះ នឹងត្រូវបានសម្រេចឲ្យចូលជាសមាជិកបម្រុងរយៈពេល ០៦ខែ។
- ការសម្រេចនេះ គឺធ្វើឡើងក្នុងគោលបំណងពិនិត្យទៅលើលទ្ធភាព និងលក្ខណៈសម្បត្តិក្នុងការចូលរួមក្នុងសកម្មភាពក្នុងក្របខ័ណ្ឌអង្គការ ។ បន្ទាប់ពីរយៈពេលនេះត្រូវបានបញ្ចប់ ក្រុមប្រឹក្សាភិបាលជាអ្នកពិនិត្យ និងសម្រេចក្នុងការអនុញ្ញាតជាលាយលក្ខណ៍អក្សរឲ្យចូលជាសមាជិកពេញសិទ្ធិ លើកលែងតែមានការស្នើសុំពិសេសពីគណៈគ្រប់គ្រងរបស់អង្គការ CPDD។
- បន្ទាប់ពីការសម្រេចរបស់ ក្រុមប្រឹក្សាភិបាលរបស់ អង្គការ CPDD មន្ត្រីសម្របសម្រួលការអភិវឌ្ឍសមាជិកភាពនឹងផ្ញើរលិខិតជូនដំណឹងជាផ្លូវការទីដល់អង្គការសាម៉ី។

## IV. តួនាទី ភារកិច្ច និងការបាត់បង់សមាជិកភាព

### ក. ចំពោះសមាជិកបម្រុង៖

- ចាត់តាំងអ្នកតំណាងស្របច្បាប់អចិន្ត្រៃយ៍ ០១ រូប ចូលរួមក្នុងសកម្មភាពរបស់ អង្គការ CPDD និងជនបង្គោល ០១ រូប ចូលរួមក្នុងសកម្មភាពជាមួយ អង្គការ CPDD ក្នុងករណីដែលតំណាងអវត្តមាន រឺ ទាក់ទងមិនបាន។
- ក្នុងករណីមានការផ្លាស់ប្តូរអ្នកតំណាងអចិន្ត្រៃយ៍នេះ សាមីអង្គការត្រូវចាត់តាំងអ្នកតំណាងថ្មីជាលាយលក្ខណ៍អក្សរដើម្បីជំនួស។
- ចូលរួមការប្រជុំត្រីមាស និងសកម្មភាពផ្សេងៗរបស់អង្គការ អង្គការ CPDD តាមការអញ្ជើញរបស់បុគ្គលិក ឬនាយកប្រតិបត្តិនៃ អង្គការ CPDD។
- ចូលរួមក្នុងការពិនិត្យ និងគាំទ្រទៅលើញត្តិ ឬលិខិតផ្លូវការផ្សេងៗក្នុងគោលបំណងស្របច្បាប់ និងបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ។
- ចូលរួមជាអ្នកសង្កេតការណ៍ តែពុំមានសិទ្ធិបោះ ឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល។
- ចូលរួមក្នុងការផ្តល់មតិយោបល់លើការរៀបចំគោលនយោបាយនានារបស់អង្គការ អង្គការ CPDD តែពុំមាន សិទ្ធិក្នុងការផ្តល់សម្លេងអនុម័ត។

### ខ. ចំពោះសមាជិកពេញសិទ្ធិ៖

- ចាត់តាំងអ្នកតំណាងស្របច្បាប់អចិន្ត្រៃយ៍ ០១រូប ចូលរួមក្នុងសកម្មភាពរបស់អង្គការ CPDD និងជនបង្គោល ០១ រូប ចូលរួមសកម្មភាពរបស់អង្គការ CPDD ក្នុងករណីដែលអ្នកតំណាងអវត្តមាន រឺ ទាក់ទងមិនបាន។
- ក្នុងករណីមានការផ្លាស់ប្តូរអ្នកតំណាងអចិន្ត្រៃយ៍នេះ សាមីអង្គការត្រូវចាត់តាំងអ្នកតំណាងថ្មីដោយត្រូវធ្វើការផ្តល់ពត៌មានដោយផ្ទាល់តាមរយៈប្រព័ន្ធសារអេឡិចត្រូនិច និងជាលាយលក្ខណ៍អក្សរដើម្បីជំនួស។
- ចូលរួមក្នុងការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការប្រតិបត្តិរបស់អង្គការ CPDD។
- ចូលរួមក្នុងការផ្តល់មតិយោបល់ និងអនុម័តលើការរៀបចំគោលនយោបាយនានារបស់ អង្គការ CPDD
- ចូលរួមការប្រជុំត្រីមាស និងសកម្មភាពផ្សេងរបស់អង្គការ CPDD តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬនាយកប្រតិបត្តិ។
- ចូលរួមការប្រជុំ និងសកម្មភាពផ្សេងៗរបស់អង្គការ ដែលអញ្ជើញដោយបុគ្គលិក ឬនាយកប្រតិបត្តិនៃអង្គការ CPDD។
- ចូលរួមក្នុងការពិនិត្យ និងគាំទ្រទៅលើញត្តិ ឬលិខិតផ្លូវការផ្សេងៗក្នុងគោលបំណងស្របច្បាប់ និងបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ។

- ជារៀងរាល់ចុងឆ្នាំអង្គការសមាជិកត្រូវផ្ញើរបាយការណ៍ប្រចាំឆ្នាំមកកាន់អង្គការ CPDD។

**គ. ការបាត់បង់សមាជិកភាពពី អង្គការ CPDD**

សមាជិកភាពរបស់អង្គការសមាជិកនឹងត្រូវលុបពីអង្គការ CPDDក្នុងករណីដូចខាងក្រោម៖

- ករណីសាមីអង្គការបញ្ចប់គំរោងបិទអង្គការដោយមិនបន្តសកម្មភាពអភិវឌ្ឍន៍ទៀតនៅតំបន់គោលដៅ
- មានការស្នើសុំដកសមាជិកភាពជាលាយលក្ខណ៍អក្សរពីប្រធានអង្គការសមាជិកសាមីមកប្រធានក្រុមប្រឹក្សាភិបាលរបស់អង្គការ CPDD។
- អង្គការសមាជិកបានធ្វើទង្វើដែលនាំឲ្យប៉ះពាល់ដល់ គោលបំណង ទស្សនវិស័យ បេសកកម្ម និងគុណតម្លៃរបស់អង្គការ CPDD។
- ការខកខានពុំបានចូលរួមក្នុងសកម្មភាពរបស់ អង្គការ CPDD ក្នុងរយៈពេល ០១ឆ្នាំ បន្តបន្ទាប់ដោយពុំបានបញ្ជាក់ពីមូលហេតុនៃការខកខាននេះមកក្រុមប្រឹក្សាភិបាលរបស់ អង្គការ CPDD ទោះបីមានលិខិតជូនដំណឹងពីក្រុមប្រឹក្សាភិបាល ក្នុងពេលខកខាននេះធ្វើឡើងតាំពី ០៣ខែដំបូងមក។
- ការខកខានពុំបានបង់វិភាគទានអង្គការសមាជិកភាពក្នុងរយៈពេល ១២ ខែ ចុងក្រោយដោយពុំបានផ្តល់មូលហេតុជាលាយលក្ខណ៍អក្សរមកនាយកប្រតិបត្តិរបស់អង្គការ CPDD។
- បុគ្គល ឬអង្គការសមាជិកដែលបានអនុវត្ត និងប្រកាន់និន្នាការនយោបាយនៅក្នុងកិច្ចការងារអភិវឌ្ឍ និងសហប្រតិបត្តិការ
- បុគ្គល ឬអង្គការសមាជិក បានបំប្លែងអង្គការរបស់ខ្លួនទៅជាអង្គការមួយផ្សេងទៀតដោយធ្វើការផ្លាស់ប្តូរឈ្មោះ ឡូហ្គោ គោលបំណង ទស្សនវិស័យ បេសកកម្ម ទិសដៅ និងគុណតម្លៃរបស់ខ្លួន ដោយបម្រើឬមិនបម្រើឧត្តមប្រយោជន៍របស់កុមារ (ក្នុងករណីនេះ ប្រសិនបើអង្គការសាមីនៅតែចាប់អារម្មណ៍ចូលជាអង្គការសមាជិករបស់អង្គការ CPDD បុគ្គល ឬអង្គការនោះ អាចដាក់ពាក្យស្នើសុំ ជាថ្មីមក អង្គការ CPDD ដើម្បីចូលជាអង្គការសមាជិក)។
- ករណីអង្គការសមាជិកមានបញ្ហាទំនាស់នឹងច្បាប់ ដូចជាករណីរំលោភបំពានលើកុមារ ការគេងប្រវ័យផ្សេងៗ ការបន្លំ និងអំពើពុករលួយ ដែលបង្កឱនភាពដល់ស្ថាប័ន។
- ករណីអង្គការសមាជិកមាននិន្នាការបំរើនយោបាយ រឺគណបក្សណាមួយដែលប្រាសចាកពីតម្លាភាព និងគោលបំណងរបស់អង្គការនោះ ដូចច្នេះ អង្គការ CPDD នឹងធ្វើការដកចេញពីសមាជិកភាព។

V. **ប្រាក់ឧភាគទាន នីទធីនៃការបង់ និងប្រើប្រាស់ឧភាគទាន អង្គការសមាជិកភាពប្រចាំឆ្នាំ**

**ក. ប្រាក់វិភាគទាន៖**

អង្គការសមាជិករបស់អង្គការ CPDD ត្រូវបង់ប្រាក់វិភាគទានអង្គការសមាជិកភាពប្រចាំឆ្នាំទៅតាមប្រភេទអង្គការសមាជិក ដូចខាងក្រោម ៖

- ***អង្គការអន្តរជាតិ ចំនួន ១០០ ដុល្លារសហរដ្ឋអាមេរិច***
- ***បុគ្គល អង្គការជាតិ ឬអង្គការក្នុងស្រុក ចំនួន ៥០ ដុល្លារសហរដ្ឋអាមេរិក***

ការបង់ប្រាក់វិភាគទានប្រចាំឆ្នាំត្រូវធ្វើឡើងតាមការស្នើសុំចាលាយលក្ខណ៍អក្សរពីនាយកប្រតិបត្តិនៃអង្គការ CPDD នៅរៀងរាល់ខែ**មករា** នៃឆ្នាំសារពើពន្ធរបស់អង្គការ CPDD ។ ក្នុងករណីបុគ្គល អង្គការជាតិ ឬអង្គការអន្តរជាតិមួយពុំមានលទ្ធភាពបង់ប្រាក់វិភាគទានប្រចាំឆ្នាំតៅតាមការកំណត់ខាងលើ ឬបង់តាមលទ្ធភាពដែលខ្លួនមាន។ បុគ្គល ឬអង្គការសមាជិកនោះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកនាយកប្រតិបត្តិនៃអង្គការ CPDD ដើម្បីបញ្ជាក់ពីមូកហេតុពិតនៃកង្វះខាត។

**ខ. និតិវិធីនៃការបង់វិភាគទាន**

ក្នុងការធ្វើដំណើរការបង់ប្រាក់វិភាគទានប្រចាំឆ្នាំដល់ អង្គការ CPDD យើងមាន២និតិវិធី។

**១/. និតិវិធីទី១៖** ការបង់ប្រាក់វិភាគទានប្រចាំឆ្នាំតាមរយៈផ្ទេរទៅគណនីធនាគាររបស់អង្គការ អង្គការ CPDD ដូចខាងក្រោម៖

- ធនាគារ៖ អេស៊ីលីដា, រាជធានីភ្នំពេញ
- ឈ្មោះគណនី៖ CPDD coalition for Partnership in Democratic Development
- លេខគណនី៖ **2900-0272-2266-1-6**

**២/. នីតិវិធីទី២៖** ការបង់ប្រាក់វិភាគទានប្រចាំឆ្នាំតាមរយៈ ជាសាច់ប្រាក់មកកាន់ការិយាល័យអង្គការ CPDD ដោយផ្ទាល់ តាមរយៈអស័យដ្ឋានដូចខាងក្រោម៖

- អាសយដ្ឋាន៖ ភ្នំពេញវីឡា ផ្ទះលេខ ១២៤ ជាន់ទី២ បន្ទប់២០៦ ផ្លូវ៣៨៨ សង្កាត់ទួលស្វាយព្រៃ ១ ខណ្ឌចំការមន រាជធានីភ្នំពេញ។
- ប្រសិនបើលោក លោកស្រីមានសំណួរ រឺចម្ងល់ នៅក្នុងដំណើរការបង់ប្រាក់វិភាគទាន សូមទំនាក់ទំនងមកលេខទូរស័ព្ទ លោក ជា សុខាល័យ ០៧០ ៨៨ ៦៧ ៦៧ រឺ

  Email: secretariat@cpddcambodia.org

**គ. ការប្រើប្រាស់វិភាគទាន និងសិទ្ធិសម្រេច**

ការប្រើប្រាស់ប្រាក់វិភាគទានប្រចាំឆ្នាំធ្វើឡើងក្នុងក្របខ័ណ្ឌ និងដើម្បីប្រយោជន៍របស់អង្គការ CPDD គាំទ្រដល់សកម្មភាពផ្នែករដ្ឋបាល និងកម្មវិធីផ្សេងៗរបស់អង្គការ CPDD។ រាល់ការប្រើប្រាស់ប្រាក់វិភាគទានត្រូវមានយោបល់ឯកភាពពីក្រុមប្រឹក្សាភិបាល។ គណៈគ្រប់គ្រងមានសិទ្ធិក្នុងការប្រើប្រាស់ប្រាក់វិភាគទានប្រចាំឆ្នាំនេះ ដើម្បីគាំទ្រទៅដល់សកម្មភាពផ្នែករដ្ឋបាល និងកម្មវិធីរបស់អង្គការ CPDD យើងទទួលស្គាល់នូវ

ការរួមវិភាគទាន និងការរំពឹងទុក របស់អង្គការសមាជិកដទៃទៀត ដើម្បីរក្សា និងបង្កើនកិច្ចសហប្រតិបត្តិការ និងការគោរពគ្នាទៅវិញទៅមក។

**ឃ. ព័ត៌មានទំនាក់ទំនងសម្រាប់ដាក់ពាក្យស្នើសុំចូលជាសមាជិកភាព**

- បណ្ដាបុគ្គល និងអង្គការមិនមែនរដ្ឋាបាលជាតិ និងអន្តរជាតិដែលចង់ចូលជាសមាជិក អង្គការ CPDD អាចចូលទៅក្នុងLink: .................. ដើម្បីទាញយកពាក្យសស្នើសុំ និងការណែនាំរបស់ អង្គការ CPDD លើកទឹកចិត្តដល់បណ្ដាបុគ្គល និងអង្គការមិនមែនរដ្ឋាបាលជាតិ និងអន្តរជាតិស្វែងយល់ពី អង្គការ CPDD តាមរយៈគេហទំព័រ៖ https://forms.office.com/r/K6d5eFY7y8 ។
- ឬបណ្ដាបុគ្គល និងអង្គការមិនមែនរដ្ឋាបាលជាតិ និងអន្តរជាតិអាចយកពាក្យស្នើសុំចូលជាអង្គការសមាជិកតាមរយៈអ៊ីម៉ែល៖ info@cpddcambodia.org

  អាសយដ្ឋាន៖ ភ្នំពេញវីឡា ផ្ទះលេខ ១២៤ ជាន់ទី២ បន្ទាប់២០៦ ផ្លូវ៣៨៨ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ។

  ទំនងមកលេខទូរស័ព្ទ លោក ជា សុខាល័យ ០៧០ ៨៨ ៦៧ ៦៧

## VI. ការកែប្រែគោលការណ៍ នីតិវិធី និងសិទ្ធិសម្រេច

### ក. ការកែប្រែគោលការណ៍

គោលការណ៍ណែនាំស្តីពីការចូលជាអង្គការសមាជិកភាពជាមួយ អង្គការ CPDD នឹងត្រូវប្រើប្រាស់ និង អនុវត្តពេញមួយឆ្នាំ។ រៀងរាល់ចុងឆ្នាំ ចន្លោះខែវិច្ឆិកា និងធ្នូ អង្គការ CPDD នឹងរៀបចំសន្និបាតប្រចាំឆ្នាំ ដែលមានការចូលរួមយ៉ាងតិច ៧០ភាគរយនៃអង្គការសមាជិក ដូចនេះប្រធានក្រុមប្រឹក្សាភិបាល អង្គការ CPDD អាចត្រួតពិនិត្យឡើងវិញដើម្បីធ្វើការកែប្រែលើចំណុច ឬលក្ខខ័ណ្ឌណាមួយ។

### ខ. នីតិវិធី និងសិទ្ធិសម្រេច

អង្គការ CPDD នឹងអនុវត្តនិតិវិធី ០២យ៉ាង។ មួយវិញទៀត អង្គការ CPDD នឹងគោរពរាល់សិទ្ធិសម្រេចទៅដល់ក្រុមប្រឹក្សាភិបាលរបស់ អង្គការ CPDD ចំពោះការកែប្រែ និងសម្រេចលើការណែនាំនេះ។

**១/. និតិវិធីទី១៖** ប្រធានក្រុមប្រឹក្សាភិបាល អង្គការ CPDD អាចត្រួតពិនិត្យឡើងវិញដើម្បីធ្វើការកែប្រែលើចំណុច ឬលក្ខខ័ណ្ឌណាមួយនៅក្នុងកម្មវិធីសន្និបាតប្រចាំឆ្នាំ។

**២/.និតិវិធីទី១៖** ក្នុងករណីបន្ទាន់ ឬចាំបាច់ដោយមានការស្នើរសុំក្នុងធ្វើការកែប្រែលើចំណុច ឬលក្ខខ័ណ្ឌណាមួយនៅក្នុងគោលការណែនាំស្តីពីការចូលជាអង្គការសមាជិក ដោយមានសំលេងពីអង្គការសមាជិក៥០ភាគរយបូកមួយ ក្នុងការស្នើសុំធ្វើការកែប្រែនេះ។ អង្គការ CPDD នឹងធ្វើការស្នើសុំទៅកាន់ប្រធានក្រុមប្រឹក្សាភិបាលធ្វើការសម្រេចលើការស្នើសុំនោះតាមរយៈការប្រជុំត្រីមាសជាមួយប្រធានក្រុមប្រឹក្សាភិបាល។

| | | |
|---|---|---|
| រៀបចំដោយ៖ | ត្រួតពិនិត្យ | អនុម័ត្រដោយ |
| ជា សុខាល័យ | សុន ពេញ | ជេត ចរិយា |
| | | |
| មន្ត្រី | នាយក | ប្រធានក្រុមប្រឹក្សាភិបាល |